**<u>ការប្រកាសពីកិច្ចប្រជុំជាសាធារណៈ</u>**

**សំណើសុំដាក់លក់មជ្ឈមណ្ឌលវេជ្ជសាស្ត្រ St. Francis ទៅឲ្យក្រុមហ៊ុនបម្រើសេវាកម្មថែទាំសុខភាពបឋម**

អគ្គរដ្ឋអាជ្ញានៃរដ្ឋកាលីហ្វ័រញ៉ានឹងដឹកនាំកិច្ចប្រជុំជាសាធារណៈ ចាប់ពីថ្ងៃសុក្រ ទី២៦ ខែមិថុនា ឆ្នាំ២០២០ នៅវេលាម៉ោង ១០ ព្រឹក តាមរយៈកិច្ចប្រជុំតាមទូរសព្ទ ទៅលើសំណើសុំដាក់លក់មជ្ឈមណ្ឌលវេជ្ជសាស្ត្រ St. Francis ទៅឲ្យក្រុមហ៊ុនបម្រើសេវាកម្មថែទាំសុខភាពបឋម។

ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងរបស់ជម្ងឺ កូវីត១៩ អភិបាល ញ៉ូសម បានដាក់ឲ្យប្រើប្រាស់នូវបទបញ្ជាប្រតិបត្តិ N-33-20 ដែលប្រកាសពីការដាក់រដ្ឋកាលីហ្វ័រញ៉ាឲ្យនៅក្នុងភាពមានអាសន្ន និងបញ្ជាឲ្យបុគ្គលដែលរស់នៅ ក្នុងរដ្ឋកាលីហ្វ័រញ៉ាទាំងអស់ ស្ថិតនៅក្នុងផ្ទះ ឬកន្លែងដែលពួកគេស្នាក់នៅ លើកលែងតែមានការចាំបាច់ ដើម្បីរក្សាការបន្តប្រតិបត្តិការនៃវិស័យហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់សហព័ន្ធ។ អភិបាល ញ៉ូសម ក៏បានដាក់ឲ្យប្រើប្រាស់នូវបទបញ្ជាប្រតិបត្តិ N-25-20 និង N-29-20 ដែលផ្តល់សិទ្ធិអំណាចដល់អគ្គរដ្ឋអាជ្ញាដើម្បីរៀបចំកិច្ចប្រជុំជាសាធារណៈតាមរយៈទូរសព្ទ ដោយមិនផ្តល់នូវទីតាំងជាក់លាក់ ដែលសមាជិកនៃសាធារណៈជនអាចតាមដានកិច្ចប្រជុំ និងផ្តល់ជាមតិយោបល់ជាសាធារណៈឡើយ។

កិច្ចប្រជុំជាសាធារណៈ នឹងអាចឲ្យសាធារណៈជនចូលទៅដល់ តាមរយៈទូរស័ព្ទនិងប្រព័ន្ធអេឡិចត្រូនិច។ សាធារណៈជនអាចស្តាប់កិច្ចប្រជុំជាសាធារណៈ ឬ អាចជំនួសដោយការតាមដាន ស្តាប់ និងផ្តល់ជាមតិយោបល់ ដោយប្រើប្រាស់នូវមធ្យោបាយដូចបានរៀបរាប់ខាងក្រោម៖

**ការប្រកាសពីកិច្ចប្រជុំជាសាធារណៈនេះ ត្រូវបានដាក់នៅក្នុងគេហទំព័ររបស់អគ្គរដ្ឋអាជ្ញា ជាមួយនឹងតំណរភ្ជាប់ និងសេចក្តីណែនាំអំពីការចូលរួមកិច្ចប្រជុំជាសាធារណៈ ដោយកម្មវិធី BlueJeans videoconference។**

**https://oag.ca.gov/charities/nonprofithosp**

ក្នុងកំឡុងពេលប្រជុំ អ្នកចូលរួមទាំងអស់នឹងត្រូវបានដាក់ឲ្យបិទសម្លេង ដោយអ្នកសម្របសម្រួល។ អ្នកនឹងមិនអាចបិទ ឬ បើកសម្លេងដោយខ្លួនឯងបានទេ។

**<u>សេចក្តីណែនាំអំពីការចូលរួមកិច្ចប្រជុំជាសាធារណៈ</u>**

**<u>ការប្រើកុំព្យូទ័រ តាមរយៈ Google Chrome Web Browser ឬ កម្មវិធី BlueJeans Events</u>**

ដើម្បីផ្តល់ឲ្យអ្នកប្រើប្រាស់នូវបទពិសោធន៍ដ៏ល្អបំផុត BlueJeans សូមណែនាំឲ្យប្រើ Google Chrome web browser ឬ ទាញយក [កម្មវិធី BlueJeans Events] ដោយឥតគិតថ្លៃ។

វានឹងអាចអនុញ្ញាតឲ្យអ្នកចូលរួម បានតាមដាន ស្តាប់ និងផ្តល់ជាមតិយោបល់ នៅក្នុងកិច្ចប្រជុំជាសាធារណៈនេះ។ អ្នកចូលរួមអាចផ្តល់ជាមតិយោបល់តាមរយៈ ការសរសេរ ឬ និយាយដោយពាក្យសម្តី ដោយប្រើប្រាស់នូវតំណរភ្ជាប់ខាងក្រោម៖ https://primetime.bluejeans.com/a2m/live-event/fffjytvf

សំណើសុំទំនាក់ទំនងដោយផ្ទាល់ ដើម្បីផ្តល់នូវមតិយោបល់ជាពាក្យសម្តីដោយ៖

(1) ជ្រើសរើសរូបសញ្ញាលើកដៃ នៅផ្នែកខាងស្តាំនៃអេក្រង់របស់អ្នក។

(2) បន្ទាប់ពីទទួលបានការយល់ព្រមពីអ្នកសម្របសម្រួលហើយ ជ្រើសរើសពាក្យថា បន្ត។
(3) បន្ទាប់មក អ្នកនឹងត្រូវបានបញ្ជូនឲ្យទៅចាំនៅក្នុងជួរ។

សូមរង់ចាំដើម្បីនិយាយ រហូតទាល់តែអ្នកសម្របសម្រួល អញ្ជើញអ្នកឲ្យផ្តល់មតិយោបល់របស់អ្នក។ បន្ទាប់មក អ្នកសម្របសម្រួលនឹងបើកមីក្រូហ្វូនរបស់អ្នក។ **អ្នកត្រូវតែមានមីក្រូហ្វូនដើម្បីបញ្ចេញនូវមតិយោបល់របស់អ្នក។**

## ឧបករណ៍ចល័ត

ប្រើប្រាស់ឧបករណ៍ចល័ត ដូចជា ទូរសព្ទចល័ត ឬ tablet នឹងអនុញ្ញាតឲ្យអ្នកចូលរួម តាមដាន ស្តាប់ និងផ្តល់ជាមតិយោបល់នៅក្នុងកិច្ចប្រជុំជាសាធារណៈ ប្រសិនបើពួកគេទាញយកកម្មវិធី BlueJeans។

ប្រើនូវតំណរភ្ជាប់ខាងក្រោមដើម្បីចូលរួម ដោយប្រើប្រាស់ឧបករណ៍ចល័ត។
ជម្រើសនេះនឹងតម្រូវឲ្យអ្នកចូលរួមទាញយកកម្មវិធី BlueJeans និងអនុញ្ញាតឲ្យអ្នកចូលរួម តាមដានកិច្ចប្រជុំជាសាធារណៈ និងផ្តល់មតិយោបល់ជាសាធារណៈ។ អ្នកចូលរួមអាចផ្តល់ជាមតិយោបល់ បានដោយប្រើការសរសេរ ឬ ការនិយាយ។ ប្រសិនបើអ្នកចូលរួមមិនបានទាញយកកម្មវិធី BlueJeans ទេ អ្នកចូលរួមអាចបានត្រឹមតែ ស្តាប់ និងមិនអាច ផ្តល់ជាមតិយោបល់បានឡើយ។

a( បើកតំណរភ្ជាប់នេះ៖ https://primetime.bluejeans.com/a2m/live-event/fffjytvf

b( ទាញយកកម្មវិធី ប្រសិនបើអ្នកមិនទាន់មានវា។

c( បញ្ចូលលេខសម្គាល់របស់ព្រឹត្តិការណ៍fffjytvf

## តាមទូរសព្ទ

ប្រើប្រាស់ទូរសព្ទនឹងអនុញ្ញាតឲ្យអ្នកចូលរួម ស្តាប់តែកិច្ចប្រជុំជាសាធារណៈ ប៉ុន្តែនឹងមិនអនុញ្ញាតឲ្យអ្នកចូលរួម តាមដានកិច្ចប្រជុំជាសាធារណៈ ឬ ផ្តល់ជាមតិយោបល់ឡើយ។
ទំនាក់ទំនងទៅលេខមួយ ក្នុងចំណោមលេខទូរសព្ទខាងក្រោម៖

a) +1 (415) 466-7000 (សហរដ្ឋអាមេរិក)

បញ្ចូលលេខកូដសម្ងាត់៖ 1270051 ភ្ជាប់ដោយ #

b) +1 (760) 699-0393 (សហរដ្ឋអាមេរិក)

បញ្ចូលលេខកូដសម្ងាត់៖ 2198758648 ភ្ជាប់ដោយ #

## ជំនួយពី BlueJeans

លេខទូរសព្ទក្នុងការបម្រើសេវាកម្មអតិថិជនរបស់ BlueJeans គឺ៖ +1 (408) 791-2830
អ្នកចូលរួមក៏អាចស្វែងរកជំនួយនៅ៖ https://support.bluejeans.com

**<u>គោលបំណងនៃកិច្ចប្រជុំជាសារធារណៈ</u>**

គោលបំណងនៃកិច្ចប្រជុំជាសារធាណៈនេះ គឺដើម្បីឲ្យទទួលបាននូវមតិយោបល់អំពីសំណើសុំដាក់លក់មន្ទីរពេទ្យ និងដើម្បីធ្វើការពិចារណាអំពីរបាយការណ៍នៃផលប៉ះពាល់ចំពោះការថែទាំសុខភាព ដែលរៀបចំដោយអ្នកប្រឹក្សាយោបល់ ដោយមានការចូលរួមពីអគ្គរដ្ឋអាជ្ញានៃរដ្ឋកាលីហ្វ័រញ៉ា។ នៅមុនពេលកិច្ចប្រជុំជាសាធារណៈនេះ របាយការណ៍នៃផលប៉ះពាល់ចំពោះការថែទាំសុខភាព នឹងអាចស្វែងរកបាននៅលើគេហទំព័ររបស់អគ្គរដ្ឋអាជ្ញានៃរដ្ឋកាលីហ្វ័រញ៉ានៅ http://www.oag.ca.gov/charities/nonprofithosp។

**បុគ្គលនានាត្រូវបានលើកទឹកចិត្ត ឲ្យបង្ហាញពីទស្សនៈយល់ឃើញរបស់ពួកគេ ចំពោះប្រតិបត្តិការនៃសំណើសុំ ជាលាយលក្ខណ៍អក្សរ ទៅកាន់ការិយាល័យអគ្គរដ្ឋអាជ្ញានៃរដ្ឋកាលីហ្វ័រញ៉ា ក្នុងទម្រង់អេឡិចត្រូនិកទៅកាន់ scott.chan@doj.ca.gov តាមរយៈសំណៅថតចម្លងលេខ (415( 703-5480 ឬផ្ញើសំណៅថតចម្លងតាមប្រៃសណីយ៍ទៅកាន់ Scott Chan អគ្គរដ្ឋអាជ្ញារង តាមរយៈអាសយដ្ឋាន 455 Golden Gate Avenue, Suite 11000, San Francisco, CA 94102។ រយៈពេលផុតកំណត់នៃការទទួលមតិយោបល់ជាលាយលក្ខណ៍អក្សរនេះ គឺនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ នៅម៉ោង ៥ ល្ងាច។**

សេចក្តីអធិប្បាយនៃការប្រកាសខាងលើ ក៏អាចស្វែងរកបានជាមួយនឹងភាសាផ្សេងៗផងដែរ

អារ៉ាប់, អាមេនី, កម្ពុជា, ចិន (កាតាំង), ចិន (កុកងឺ), អង់គ្លេស, ហ្វាសុី, កូរ៉េ, រុស្សុី, អេស្ប៉ាញ, តាហ្គាឡុក និងវៀតណាម។